# កិច្ចព្រមព្រៀង

# ស្តីពី

# ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

# រវាង

នាយករោងចក្រ និង ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

**កម្មវត្ថុ** សំណើសុំព្យួរកិច្ចសន្យាកាងារ កម្មករនិយោជិតចំនួន ៦៣១ នាក់រយៈពេល៣១ថ្ងៃ។

**យោង** មាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាសគ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩ លេខ:០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃពុធ ៤កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ស្វាយរៀង ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២០។

ថ្ងៃទីម្ភៃបួន ខែមិថុនា ឆ្នាំពីរពាន់ម្ភៃ វេលាម៉ោង១៥ និង៣០នាទី មានកិច្ចប្រជុំនៅរោងចក្រកាត់ដេរសម្លៀកបំពាក់

**ស៊ីកូ (ខេមបូឌា) ខូអិលធីឌី**

បានព្រមព្រៀង និងឯកភាពគ្នាដូចខាងក្រោម

១-ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតផ្នែកវេចខ្ចប់ទាំងអស់សរុបចំនួន៦៣១ នាក់រយៈពេល៣១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ខែកក្កដាឆ្នាំ២០២០។

២-នាយករោងចក្រ និងប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត បានព្រមព្រៀងផ្តល់ប្រាក់ចំនួន ៣០ ដុល្លារអាមេរិក ចំពោះកម្មករដែលព្យួរការងារបើកលុយរៀងរាល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ គឺបើកតាមធានាគារ អេស៊ីលីដា ហើយកម្មករដែលនៅសល់បើកពីក្រុមហ៊ុនដោយ ផ្ទាល់ដៃ និងរាជរដ្ឋាភិបាលឧបត្ថម្ភ៤០ដុល្លារអាមេរិក។

៣-ចូលធ្វើការវិញនៅថ្ងៃទី០១ ខែ សីហា ឆ្នាំ២០២០។ កំណត់ហេតុនៃកិច្ចព្រមព្រៀងនេះ បានចប់សព្វគ្រប់នៅថ្ងៃ ខែ ឆ្នាំដដែលវេលាម៉ោង១៦ និង ០០នាទី ក្រោមបរិយាកាសរីករាយ ឯកភាពគ្នា និងភាពស្និទ្ធស្នាលក្រៃលែង។

ស្វាយរៀង ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

ស្នាមមេដៃស្តាំប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

CHIEN,CHIH PIN

SHEICO (CAMBODIA) CO., LTD.